**អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន**
**និងសង្គ្រោះជនពិការដោយសារមីន**

# ផែនការបញ្រ្ជាបយេនឌ័រក្នុងវិស័យសកម្មភាពមីន
# ២០២១-២០២៥






រៀបចំដោយ៖ ក្រុមការងារយេនឌ័រអាជ្ញាធរមីន

ឆ្នាំ២០២១

ឧបត្ថម្ភដោយ៖ UNDP

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការពង្រឹងសមភាពយេនឌ័រនៅគ្រប់កម្រិត និងគ្រប់វិស័យ និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ ដោយដាក់បញ្ចូលការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រជាតិសំខាន់ៗ។ ផ្អែកលើមូលដ្ឋាននេះ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ត្រូវបានកំណត់ជាគោលដៅដ៏សំខាន់មួយនៅក្នុងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ (NMAS 2018-2025) ដែលជាផែនទីបង្ហាញផ្លូវដល់គ្រប់ប្រតិបត្តិករសកម្មភាពមីនជាតិ-អន្តរជាតិទាំងអស់ រួមទាំងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធផ្សេងទៀតដែលចូលរួមអនុវត្តសកម្មភាពមីននៅកម្ពុជា។

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (ហៅកាត់ថា អាជ្ញាធរមីន) ដែលជាសេនាធិការឲ្យរាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលវិស័យសកម្មភាពមីននៅកម្ពុជា បានសហការជាមួយគ្រប់ភាគីពាក់ព័ន្ធធ្វើបច្ចុប្បន្នភាព និងកសាងផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន (GMAP) ២០២១-២០២៥ ស្របតាមអាណត្តិរបស់ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ដើម្បីធានាថាសេចក្តីកង្វល់ បទពិសោធន៍ និងតម្រូវការរបស់ស្ត្រី បុរស កុមារី កុមារា និងជនមានពិការភាព ត្រូវបានយកចិត្តទុកដាក់ពិចារណាក្នុងការរៀបចំ អនុវត្តន៍ តាមដានត្រួតពិនិត្យ និងវាយតម្លៃក្នុងកម្មវិធីសកម្មភាពមីននានា ដែលនេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ និងការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធដទៃទៀត ដែលជាការរួមចំណែកដល់កិច្ចអភិវឌ្ឍន៍សង្គមជាតិ។

ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានអាជ្ញាធរមីន** ខ្ញុំសូមថ្លែងអំណរគុណចំពោះកិច្ចសហការយ៉ាងល្អពីគ្រប់ក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ប្រតិបត្តិករសកម្មភាពមីនជាតិ-អន្តរជាតិ និងភាគីពាក់ព័ន្ធទាំងអស់ ក្នុងការផ្តល់ធាតុចូល និងអនុសាសន៍ដ៏មានតម្លៃមកកាន់អាជ្ញាធរមីន ជាពិសេសកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា (UNDP Cambodia) ដែលបានផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ការកសាងផែនការនេះ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំជឿជាក់ថា គ្រប់ក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ប្រតិបត្តិករសកម្មភាពមីនជាតិ-អន្តរជាតិ និងភាគីពាក់ព័ន្ធទាំងអស់ នឹងបន្តចូលរួមផ្តល់កិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥ នេះ ប្រកបដោយជោគជ័យ ប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបាននូវការលើកកម្ពស់សមភាពនិងសមធម៌យេនឌ័រ និងគោលដៅរួមឆ្ពោះទៅរកកម្ពុជាមួយគ្មានមីនត្រឹមឆ្នាំ២០២៥។ល

ថ្ងៃចន្ទ ២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានទី១**

**លី ធុជ**

# មាតិកា


**ពាក្យបំព្រួញ**........................................................................................................៤

**១. សេចក្តីផ្តើម** ........................................................................................................៥

**២. គោលបំណង** ........................................................................................................៦

**៣. ផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥** ..........................៦

យុទ្ធសាស្ត្រទី១៖ ធ្វើបច្ចុប្បន្នភាព និងពង្រឹងការអនុវត្ត GMAP និងគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ..........................................................៦

- លទ្ធផលរំពឹងទុក ១.១៖ ....................................................................................... ៦
- លទ្ធផលរំពឹងទុក ១.២៖ ....................................................................................... ៦

យុទ្ធសាស្ត្រទី២៖ ពង្រឹងសមត្ថភាពអាជ្ញាធរមីន ម៉ាពូ ប្រតិបត្តិករ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាន ក្នុងការអនុវត្តគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន................................................................................................ ៧

- *លទ្ធផលរំពឹងទុក ២.១៖* .......................................................................................៧
- *លទ្ធផលរំពឹងទុក ២.២៖* ....................................................................................... ៧

យុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការចូលរួមប្រកបដោយស្មើភាពរបស់ស្ត្រី ក្នុងដំណើរការសកម្មភាពមីន ក្នុងសេវាកម្មសម្រាប់អ្នកនៅរស់រានមានជីវិត ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (EORE) និងក្នុងសកម្មភាពស្វែងរកការគាំទ្រមតិ ..........................៧

- *លទ្ធផលរំពឹងទុក ៣.១៖*.......................................................................................៧
- *លទ្ធផលរំពឹងទុក ៣.២៖*.......................................................................................៨
- *លទ្ធផលរំពឹងទុក ៣.៣៖*.......................................................................................៨

**៤. ប្រភពហិរញ្ញវត្ថុ** ........................................................................................................៨

**៥. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ** ..........................................................................៩

**៦. សេចក្តីសន្និដ្ឋាន** ........................................................................................................១០

**ឧបសម្ព័ន្ធ ១៖** គម្រោងផែនការលម្អិត.......................................................................................១១

# ពាក្យបំព្រួញ

| | |
|---|---|
| អាជ្ញាធរមីន | អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន |
| ស.ក.ម.ក. | ស្តង់ដាកម្ចាត់មីនកម្ពុជា |
| ផ.យ.ជ.ម. | ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន |
| ភីម៉ាក់ | គណៈកម្មាធិការផែនការសកម្មភាពមីនខេត្ត |
| ម៉ាពូ | អង្គភាពផែនការសកម្មភាពមីនខេត្ត |
| ស.ផ.ស. | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| CMAA-GT | ក្រុមការងារយេនឌ័រអាជ្ញាធរមីន |
| DBU | អង្គភាពទិន្នន័យ |
| EORE | ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ |
| GICHD | មជ្ឈមណ្ឌលអន្តរជាតិហ្សឺណែវសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ |
| GMAP | ផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន |
| PRD | នាយកដ្ឋានទំនាក់ទំនងសាធារណៈ |
| PwD | ជនមានពិការភាព |
| PWDF | មូលនិធិជនពិការ |
| QLS | ការសិក្សាពីគុណភាពជីវិត |
| QMT | ក្រុមគ្រប់គ្រងគុណភាព |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SADD | ទិន្នន័យបែងចែកភេទ-អាយុ |
| TRG-Gender | ក្រុមការងារបច្ចេកទេសផ្នែកបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| VA | កិច្ចសង្គ្រោះជនរងគ្រោះថ្នាក់ដោយសារមីន |
| VAD | នាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន |

## ១. សេចក្តីផ្តើម

សមភាពនិងសមធម៌យេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី គឺជាយុទ្ធសាស្ត្រមួយដែលត្រូវបានចាត់ជាអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្រ អភិបាលកិច្ចល្អ ការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ច។ ការទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជាលើចំណុចនេះ ស្តែងចេញតាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បី «កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព» គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា គោលដៅទី៨ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ២០១៩-២០២៣ ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងកុមារ ២០១៩-២០២៣ និងការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយនានា កម្មវិធីកំណែទម្រង់សាធារណៈ និងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិនិងតាមវិស័យ។

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា គឺជាការធានានូវវឌ្ឍនភាព និងឱកាសនាពេលអនាគតក្នុងវិស័យជាច្រើននៅកម្ពុជា។ វិស័យសកម្មភាពមីនគិតគូរពីតួនាទី និងទំនួលខុសត្រូវផ្សេងៗរបស់ស្ត្រី បុរស កុមារី កុមារា និងជនមានពិការភាព ជាពិសេសទាក់ទងនឹងហានិភ័យ ការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលបានធនធានឬជំនួយ និងអត្ថប្រយោជន៍ផ្សេងៗពីវិស័យសកម្មភាពមីន។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាលើកកម្ពស់សមភាពនិងសមធម៌យេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី ដោយដាក់បញ្ចូលការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការយុទ្ធសាស្ត្រជាតិសម្មភាពមីន ក្រោម**គោលបំណងទី៨** និង**គោលដៅទី៣**។

**គោលបំណងទី៨៖** ធានារាល់សកម្មភាពមីនទាំងអស់ត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាពដែលមានភាពល្អប្រសើរ ការគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ការយកចិត្តទុកដាក់ខ្ពស់អំពីយេនឌ័រ និងការការពារបរិស្ថាន។

**គោលដៅទី៣៖ ជំរុញការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពមីន**

**យុទ្ធសាស្ត្រ៖**

១. កសាងផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន (GMAP) និងគោលការណ៍ណែនាំអំពីការបញ្ជ្រាបយេនឌ័រ។

២. ពង្រឹងសមត្ថភាពរបស់អាជ្ញាធរមីន អង្គភាពផែនការសកម្មភាពមីន (ម៉ាពូ) ប្រតិបត្តិករ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាន ក្នុងការអនុវត្តគោលការណ៍ណែនាំអំពីការបញ្ជ្រាបយេនឌ័រ។

៣. លើកកម្ពស់ការចូលរួមប្រកបដោយស្មើភាពរបស់ស្ត្រី ក្នុងដំណើរការសកម្មភាពមីន ក្នុងសេវាកម្មសម្រាប់អ្នកនៅរស់រានមានជីវិត ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (EROE) និងក្នុងសកម្មភាពស្វែងរកការគាំទ្រមតិ។

ដើម្បីអនុវត្ត ផ.យ.ជ.ម. ខាងលើ អាជ្ញាធរមីនបានកសាងផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន (GMAP) ២០១៣-២០១៥ និងផែនការបន្ត (GMAP) ២០១៨-២០២២ ដោយបានដាក់ចេញនូវសកម្មភាពនិងសូចនាករលម្អិត ដើម្បីជំរុញសមភាពយេនឌ័រនៅក្នុងសកម្មភាពមីន។ (GMAP) ២០១៨-២០២២ ត្រូវបានវាយតម្លៃដោយ មជ្ឈមណ្ឌលអន្តរជាតិហ្សឺណែវសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ (GICHD) ថាជាផែនការដែលត្រូវបានកសាងយ៉ាងល្អ ដោយមានបញ្ចូលនូវសូចនាករ និងសកម្មភាពការងារ

នានា ដែលជួយពង្រឹងនូវការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីននៅកម្ពុជា ទទួលបានជោគជ័យ។ ទោះបីជាយ៉ាងណាក៏ដោយ នៅមានបញ្ហាប្រឈមមួយចំនួន ដែលទាមទារឱ្យមានវិធានការហ្មត់ចត់ និងតម្រូវឱ្យមានការកសាង GMAP ២០២១-២០២៥។

## ២. គោលបំណង

ផែនការនេះត្រូវបានកសាងឡើង ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រដែលបានកំណត់នៅក្នុងគោលដៅទី៣ គោលបំណងទី៨ នៃផ.យ.ជ.ម ដើម្បីជាជំនួយសម្រាប់អាជ្ញាធរមីន និងភាគីពាក់ព័ន្ធក្នុងវិស័យសកម្មភាពមីននៅកម្ពុជា ក្នុងការបញ្ជ្រាបយេនឌ័រ និងជំរុញកិច្ចខិតខំប្រឹងប្រែងឱ្យមានសមភាពនិងសមធម៌យេនឌ័រ នៅគ្រប់សកម្មភាពមីន។ ផែនការនេះក៏ជាផែនទីបង្ហាញផ្លូវក្នុងការដឹកនាំ និងការអនុវត្តការបញ្ជ្រាបយេនឌ័រនៅក្នុងការរៀបចំផែនការ ការអនុវត្ត និងការវាយតម្លៃលើគ្រប់កម្មវិធីសកម្មភាពមីន។

## ៣. ផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥

ផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីនរយៈពេល៥ឆ្នាំ (២០២១-២០២៥) ត្រូវបានកំណត់ដូចតទៅ៖

**យុទ្ធសាស្ត្រទី១៖ ធ្វើបច្ចុប្បន្នភាព និងពង្រឹងការអនុវត្ត GMAP និងគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន**

- ***លទ្ធផលរំពឹងទុក ១.១៖*** *ផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីនឆ្នាំ ២០២១-២០២៥ ត្រូវបានកសាង និងគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ត្រូវបានកែសម្រួល*

  **សកម្មភាព៖**

  ១. កសាងផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥
  ២. ផ្សព្វផ្សាយផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥ ទៅកាន់ភាគីពាក់ព័ន្ធ
  ៣. កែសម្រួលគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន

- ***លទ្ធផលរំពឹងទុក ១.២៖*** *យន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃនៃការអនុវត្តGMAPត្រូវបានពង្រឹង*

  **សកម្មភាព៖**

  ១. តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តគោលការណ៍ណែនាំ ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីនរបស់ម៉ាពូ ក្រុមត្រួតពិនិត្យ និងប្រតិបត្តិករ
  ២. កសាងផែនការសកម្មភាពប្រចាំឆ្នាំ និងទម្រង់របាយការណ៍វឌ្ឍនភាពសកម្មភាពការងារយេនឌ័រប្រចាំត្រីមាសនិងប្រចាំឆ្នាំ របស់ក្រុមការងារយេនឌ័រអាជ្ញាធរមីន
  ៣. រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារយេនឌ័រអាជ្ញាធរមីន និងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន យ៉ាងតិចម្តងក្នុងមួយឆ្នាំ

៤. រៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិ និងពេលបញ្ចប់ការអនុវត្តផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន

**យុទ្ធសាស្ត្រទី២៖ ពង្រឹងសមត្ថភាពអាជ្ញាធរមីន ម៉ាពូ ប្រតិបត្តិករ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន**

- ***លទ្ធផលរំពឹងទុក ២.១៖*** *សមត្ថភាពសមាជិកក្រុមការងារយេនឌ័រអាជ្ញាធរមីន ម៉ាពូ ប្រតិបត្តិករ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋានត្រូវបានពង្រឹង*

  **សកម្មភាព៖**

  ១. បណ្តុះបណ្តាលសមាជិកក្រុមការងារយេនឌ័រអាជ្ញាធរមីន ស្តីពីនីតិវិធីសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ លើការអនុវត្តគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន និង GMAP 2021-2025

  ២. បណ្តុះបណ្តាលមន្ត្រី-បុគ្គលិកអាជ្ញាធរមីន ម៉ាពូ ក្រុមត្រួតពិនិត្យ និងប្រតិបត្តិករក្នុងការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន

  ៣. ប្រមូលទិន្នន័យ និងចងក្រងរបាយការណ៍ប្រចាំឆ្នាំនៃការបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបយេនឌ័រ ដែលអាជ្ញាធរមីន ម៉ាពូ និងប្រតិបត្តិករទទួលបានពីភាគីពាក់ព័ន្ធ

- ***លទ្ធផលរំពឹងទុក ២.២៖*** *របាយការណ៍ស្តីពីការកសាងសមត្ថភាពបុគ្គលិកស្ត្រីនៅក្នុងអាជ្ញាធរមីន ម៉ាពូ និងប្រតិបត្តិករ*

  **សកម្មភាព៖**

  ១. ប្រមូល និងចងក្រងរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាពបុគ្គលិកស្ត្រីរបស់អាជ្ញាធរមីន

  ២. ប្រមូល និងចងក្រងរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាពបុគ្គលិកស្ត្រីរបស់ម៉ាពូ

  ៣. ប្រមូល និងចងក្រងរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាពបុគ្គលិកស្ត្រីរបស់ប្រតិបត្តិករ

  ៤. វាយតម្លៃពីតម្រូវការសមត្ថភាពរបស់បុគ្គលិកស្ត្រីនៅក្នុងសកម្មភាពមីន និងស្វែងរកការគាំទ្រមតិលើតម្រូវការសមត្ថភាព ដែលនឹងជួយបុគ្គលិកស្ត្រីឱ្យទទួលបានឱកាសការងារក្រោយឆ្នាំ ២០២៥

**យុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការចូលរួមប្រកបដោយស្មើភាពរបស់ស្ត្រី ក្នុងដំណើរការសកម្មភាពមីន ក្នុងសេវាកម្មសម្រាប់អ្នកនៅរស់រានមានជីវិត ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (EORE) និងក្នុងសកម្មភាពស្វែងរកការគាំទ្រមតិ**

- ***លទ្ធផលរំពឹងទុក ៣.១៖*** *ទិន្នន័យដែលមានទិដ្ឋភាពយេនឌ័រ និងទិន្នន័យមានបែងចែកភេទ អាយុ និងពិការភាពដែលអាចយកមកប្រើប្រាស់បាន*

  **សកម្មភាព៖**

១. ពិនិត្យទម្រង់របាយការណ៍ដែលពាក់ព័ន្ធសកម្មភាពមីន ដើម្បីធានាបាននូវបរិយាប័ន្នក្នុងការឆ្លើយតបទៅនឹងយេនឌ័រ និងទិន្នន័យបែងចែកភេទ អាយុ និងពិការភាព

២. រៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធក្នុងវិស័យសកម្មភាពមីន ដើម្បីជូនដំណឹងអំពីបច្ចុប្បន្នភាពនៃទម្រង់របាយការណ៍

- ***លទ្ធផលរំពឹងទុក ៣.២៖*** *ការចូលរួម និងភាពជាតំណាងស្មើៗគ្នារបស់ស្ត្រី បុរស កុមារី កុមារា និងជនងាយរងគ្រោះត្រូវបានលើកកម្ពស់នៅក្នុងសកម្មភាពមីន តាមរយៈសកម្មភាពស្វែងរកការគាំទ្រមតិជាមួយភាគីពាក់ព័ន្ធ*

**សកម្មភាព៖**

១. បញ្ចូលការបញ្ជ្រាបយេនឌ័រទៅក្នុងព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹង ដែលរៀបចំឡើងដោយនាយកដ្ឋានទទួលបន្ទុករបស់អាជ្ញាធរមីន

២. ប្រមូលទិន្នន័យជនរងគ្រោះដោយសារមីន ដែលមានបែងចែកភេទ អាយុ និងពិការភាព ដើម្បីជួយសម្រួលដល់ការទទួលបានសេវាកម្មសមស្របប្រកបដោយសមធម៌ (ការសង្គ្រោះបន្ទាន់ ការថែទាំសុខភាព ការថែទាំរាងកាយ ការថែទាំផ្លូវចិត្ត ការស្តារនីតិសម្បទា ជីវភាពរស់នៅ និងសេវាផ្លូវច្បាប់)

៣. ពិនិត្យសម្ភារៈ EORE ដើម្បីធានាថា សារអប់រំចំគោលដៅសម្រាប់ស្ត្រី បុរស កុមារី កុមារា និងជនមានពិការភាព ដោយផ្អែកលើការវាយតម្លៃតម្រូវការ

៤. បង្កើតស្តង់ដារកម្ពុជាស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន

៥. ផ្តល់ការគាំទ្រគំនិតផ្តួចផ្តើមរបស់ភាគីពាក់ព័ន្ធ និងចូលរួមព្រឹត្តិការណ៍ក្នុងតំបន់និងសាកល ស្តីពីយេនឌ័រនៅក្នុងសកម្មភាពមីន

៦. វាយតម្លៃផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើស្ត្រីដែលកំពុងបម្រើការងារក្នុងវិស័យសកម្មភាពមីន

- ***លទ្ធផលរំពឹងទុក ៣.៣៖*** *ចំនួនស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងចំនួនស្ត្រីបម្រើការងារក្នុង អាជ្ញាធរមីន ម៉ាពូ និងប្រតិបត្តិករ កើនឡើងតាមរយៈការស្វែងរកការគាំទ្រមតិ*

**សកម្មភាព៖**

១. ស្វែងរកការគាំទ្រមតិដើម្បីបង្កើនចំនួនស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងចំនួនស្ត្រីបម្រើការងារក្នុងអាជ្ញាធរមីន ម៉ាពូ និងប្រតិបត្តិករ

២. សហការជាមួយនាយកដ្ឋានសង្គ្រោះជនពិការដោយសារមីននៃអាជ្ញាធរមីន និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការបង្កើនចំនួនបុគ្គលិកជាស្ត្រីនៅតាមមណ្ឌលស្តារនីតិ-សម្បទា

៣. ផលិតករណីសិក្សា និងវីដេអូ ស្តីពីស្ត្រីបម្រើការងារក្នុងវិស័យសកម្មភាពមីន

## ៤. ប្រភពហិរញ្ញវត្ថុ

ភាពជាដៃគូនៅក្នុងវិស័យសកម្មភាពមីនមនុស្សធម៌នៅកម្ពុជា មានសារៈសំខាន់សម្រាប់ភាពជោគជ័យនៅក្នុងវិស័យនេះរហូតមកទល់ពេលបច្ចុប្បន្ន ហើយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកសម្រេច

បាននូវសមិទ្ធផលធំៗកន្លងមក។ ការអនុវត្តការបញ្ជ្រាបយេនឌ័រក្នុងវិស័យមីន បានទទួលការគាំទ្រពីដៃគូរអន្តរជាតិ ជាពិសេសពី UNDP GICHD ជប៉ុន សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អូស្ត្រាលី អាល្លឺម៉ង់ ន័រវេស្សន៍ កាណាដា ហូឡង់ ណូវែលហ្សឺឡង់ ស្វីស និងសាធារណរដ្ឋប្រជាមានិតចិន។ ស្ថាប័នម្ចាស់ជំនួយទាំងនេះនៅតែជាប្រភពមូលនិធិដ៏សំខាន់ និងចាំបាច់សម្រាប់វិស័យសកម្មភាពមីន។ កម្ពុជានៅតែបន្តពង្រឹងទំនាក់ទំនងដ៏ល្អជាមួយប្រទេសម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ដែលបានកសាងឡើងតាមរយៈការជឿទុកចិត្តគ្នាទៅវិញទៅមក និងចែករំលែកសមិទ្ធផលសម្រេចបានរួមគ្នាជាច្រើនឆ្នាំកន្លងមក។

អនុលោមតាមផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ រាជរដ្ឋាភិបាលកម្ពុជាប្ដេជ្ញាធានាឱ្យបាននូវបរិយាប័ន្ន និងការគិតគូរពីយេនឌ័រនៅក្នុងវិស័យសកម្មភាពមីន ដោយធ្វើការគាំទ្រលើការសម្របសម្រួលថ្នាក់ជាតិ និងមុខងារបទបញ្ញត្តិ តាមរយៈអាជ្ញាធរមីន និងប្រតិបត្តិករនៅក្នុងការអនុវត្ត GMAP 2021-2025។ លើសពីនេះ អាជ្ញាធរមីននឹងធ្វើការកៀរគរធនធានបន្ថែម ដើម្បីបំពេញចន្លោះខ្វះខាត ដោយពង្រឹងទំនាក់ទំនងកាន់តែស៊ីជម្រៅជាមួយម្ចាស់ជំនួយចម្រុះ ស្របជាមួយនឹងការគាំទ្រពីគណៈកម្មាធិការពង្រឹងកិច្ចសហប្រតិបត្តិការ និងជំនួយរបស់សន្ធិសញ្ញាអូតាវ៉ា និងរដ្ឋជាសមាជិកក្នុងតំបន់ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ក្នុងនាមជាដៃគូចាំបាច់ ហើយយើងនឹងបន្តពង្រឹងទំនាក់ទំនងជាមួយម្ចាស់ជំនួយថ្មីៗ រួមទាំងវិស័យឯកជន។ ការភ្ជាប់ទំនាក់ទំនងជាមួយវិស័យឯកជននឹងផ្ដល់នូវមុំថ្មីមួយសម្រាប់ការប្រមូលធនធានថវិកា។

ការអនុវត្តការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យសកម្មភាពមីន មិនចាំបាច់មានភាពស្មុគស្មាញ និងការចំណាយច្រើននោះទេ។ គ្រប់ភាគីពាក់ព័ន្ធនៅក្នុងវិស័យសកម្មភាពមីនគួរប្រកាន់យកនូវវិធីសាស្ត្រសក្តិសិទ្ធភាពជាងមុន សម្រាប់ការអនុវត្តផែនការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីន ២០២១-២០២៥។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធសាស្ត្រកៀរគរធនធានសម្រាប់វិស័យសកម្មភាពមីនត្រូវបានរៀបចំឡើង ដើម្បីធានាបាននូវធនធានគ្រប់គ្រាន់សម្រាប់គាំទ្រការអនុវត្តគ្រប់សកម្មភាពនៅក្នុងវិស័យសកម្មភាពមីន ក៏ដូចជាការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន។

## ៥. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ និងវាយតម្លៃមានសារៈសំខាន់ណាស់សម្រាប់អាជ្ញាធរមីន និងក្រុមការងារយេនឌ័រ ដើម្បីវាយតម្លៃការអនុវត្ត GMAP និងប្រមូលយកទិន្នន័យអំពីបញ្ហាប្រឈម ដែលទាមទារឱ្យមានការឆ្លើយតប និងអន្តរាគមន៍។ ដើម្បីសម្រេចគោលបំណងនេះ ក្រុមការងារយេនឌ័ររៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ប្រើប្រាស់ផ្ទៃក្នុងអាជ្ញាធរមីន។ ក្នុងករណីចាំបាច់ ក្រុមការងារយេនឌ័រត្រូវផ្ដល់នូវការណែនាំទៅកាន់នាយកដ្ឋានជំនាញ ម៉ាពូ ក្រុមត្រួតពិនិត្យ និងប្រតិបត្តិករ អំពីរបៀបនៃការប្រើប្រាស់ឧបករណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីសម្របសម្រួលដល់ដំណើរការអនុវត្តការងារ និងការធ្វើសេចក្ដីរាយការណ៍។

យុទ្ធសាស្ត្រសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ និងផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន គួរត្រូវបានអនុវត្តដូចខាងក្រោម៖

- ក្រុមការងារយេនឌ័រអាជ្ញាធរមីន មានតួនាទីចម្បងក្នុងការសម្របសម្រួលការអនុវត្ត GMAP រាយការណ៍អំពីវឌ្ឍនភាពការងារជូនថ្នាក់ដឹកនាំនៅក្នុងអង្គភាព រួមទាំងដៃគូអភិវឌ្ឍន៍

- នាយកដ្ឋានពាក់ព័ន្ធក្នុងអាជ្ញាធរមីន តាមរយៈជនបង្គោលយេនឌ័រដែលបានចាត់តាំង គួរដើរតួនាទីជាភ្នាក់ងារអនុវត្ត GMAP ដោយធ្វើការរួមបញ្ចូលសកម្មភាពដែលពាក់ព័ន្ធនឹងយេនឌ័រ ទៅក្នុងផែនការសកម្មភាពរបស់ខ្លួន និងប្រកាន់ខ្ជាប់នូវយន្តការធ្វើសេចក្តីរាយការណ៍ ដើម្បីផ្តល់នូវមតិយោបល់លើវឌ្ឍនភាព និងឧបសគ្គទៅកាន់ក្រុមការងារយេនឌ័រអាជ្ញាធរមីន សម្រាប់ធ្វើការបូកសរុបសកម្មភាពយេនឌ័រ និងតាមដានពីវឌ្ឍនភាព
- ក្រុមការងារយេនឌ័រអាជ្ញាធរមីនត្រូវធ្វើការតាមដានជាប្រចាំ ដើម្បីវាយតម្លៃថាទស្សនទានយេនឌ័រត្រូវបានគិតគូរនៅក្នុងការបំពេញការងារប្រចាំថ្ងៃរបស់នាយកដ្ឋានជំនាញ និងភាគីពាក់ព័ន្ធ និងផ្តល់នូវមតិយោបល់សម្រាប់ការកែលម្អ ប្រសិនបើចាំបាច់
- សូចនាករ និងសកម្មភាពលម្អិតប្រចាំឆ្នាំ ត្រូវបានពិព័ណ៌នានៅក្នុង GMAP 2021-2025 និងនៅក្នុងផែនការសកម្មភាពវិស័យមីនរយៈពេល៣ឆ្នាំរបស់អាជ្ញាធរមីន។ សូចនាករ និងសកម្មភាពលម្អិតទាំងនេះសម្រាប់ប្រើប្រាស់ក្នុងការវាស់វែងវឌ្ឍនភាពប្រចាំឆ្នាំ ពីស្ថានភាពយេនឌ័រក្នុងវិស័យសកម្មភាពមីន។

ក្រុមការងារយេនឌ័រអាជ្ញាធរមីនគួរតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដោយសហការជាមួយនាយកដ្ឋានថ្នាក់គ្រប់គ្រង ដៃគូអនុវត្តគម្រោង និងដៃគូអភិវឌ្ឍន៍។ ការវាយតម្លៃ និងការធ្វើរបាយការណ៍ស្តីពីការអនុវត្តការងារ និងវឌ្ឍនភាពនៃការបញ្ជ្រាបយេនឌ័រគួរធ្វើឡើងជាប្រចាំឆ្នាំ និងនៅពេលវាយតម្លៃពាក់កណ្តាលអាណត្តិ និងនៅដំណាក់កាលចុងក្រោយនៃផែនការ ទៅតាមកាលបរិច្ឆេទនៃសកម្មភាពដែលបានកំណត់ និងប្រើប្រាស់ទម្រង់តាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ក្រុមការងារយេនឌ័រអាជ្ញាធរមីនគួររៀបចំកិច្ចប្រជុំប្រចាំត្រីមាស ដើម្បីពិភាក្សាពីសមិទ្ធផលសម្រេចបាន ចំណុចដែលត្រូវកែលម្អ បញ្ហាប្រឈម និងដំណោះស្រាយ។ នៅពេលដែលស្ថានភាពមានការប្រែប្រួល សកម្មភាពទាំងអស់អាចធ្វើការត្រួតពិនិត្យ និងកែសម្រួលឡើងវិញដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពដ៏សំខាន់នេះ។

## ៦. សេចក្តីសន្និដ្ឋាន

ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន គឺជាការទទួលខុសត្រូវរួមគ្នា ដែលពឹងផ្អែកលើការរួមចំណែកពីគ្រប់នាយកដ្ឋានរបស់អាជ្ញាធរមីន និងការយល់ដឹងពីភាគីពាក់ព័ន្ធ ដូចជា ម៉ាពូ ក្រុមត្រួតពិនិត្យប្រតិបត្តិករ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការសម្រេចឱ្យបាននូវសកម្មភាពការងារដែលបានកំណត់។ ភាពជោគជ័យនៃការអនុវត្តផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥ អាស្រ័យលើការប្តេជ្ញាចិត្តពីមន្ត្រី-បុគ្គលិកគ្រប់ជាន់ថ្នាក់របស់អាជ្ញាធរមីន ហើយទាមទារឱ្យមានការចូលរួម និងកិច្ចសហប្រតិបត្តិការយ៉ាងសកម្មពី ម៉ាពូ ក្រុមត្រួតពិនិត្យ ប្រតិបត្តិករ និងភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យសកម្មភាពមីន។

## ឧបសម្ព័ន្ធ១៖ គម្រោងផែនការលម្អិត

## ផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥

| សកម្មភាពគន្លឹះ | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | អ្នកទទួលខុសត្រូវ | គោលដៅ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
| **យុទ្ធសាស្ត្រទី១៖** ធ្វើបច្ចុប្បន្នភាព និងពង្រឹងការអនុវត្ត GMAP និងគោលការណ៍ណែនាំស្ដីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន | | | | | | | | |
| ***លទ្ធផលរំពឹងទុក ១.១៖*** *ផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីនឆ្នាំ ២០២១-២០២៥ ត្រូវបានកសាង និងគោលការណ៍ណែនាំស្ដីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ត្រូវបានកែសម្រួល* | | | | | | | | |
| **សកម្មភាពទី១៖** កសាងផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥ | GMAP 2021-2025 ត្រូវបានអនុម័ត | GMAP 2021-2025 | អាជ្ញាធរមីន ប្រតិបត្តិករ ភាគីពាក់ព័ន្ធ | ១ | - | - | - | - |
| **សកម្មភាពទី២៖** ផ្សព្វផ្សាយផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន ២០២១-២០២៥ ទៅកាន់ភាគីពាក់ព័ន្ធ | ចំនួនសិក្ខាសាលា/កិច្ចប្រជុំផ្សព្វផ្សាយ GMAP 2021-2025 | របាយការណ៍សិក្ខាសាលា/កិច្ចប្រជុំ | អាជ្ញាធរមីន ប្រតិបត្តិករ ភាគីពាក់ព័ន្ធ | - | ១ | - | - | - |
| | ចំនួនច្បាប់ចម្លង GMAP 2021-2025 ត្រូវបានបោះពុម្ព | ចំនួនច្បាប់ចម្លង GMAP 2021-2025 | អាជ្ញាធរមីន | ១៥០ | ១៥០ | - | - | - |
| **សកម្មភាពទី៣៖** កែសម្រួលគោលការណ៍ណែនាំស្ដីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន | គោលការណ៍ណែនាំត្រូវបានកែសម្រួល | គោលការណ៍ណែនាំដែលបានកែសម្រួល | អាជ្ញាធរមីន ប្រតិបត្តិករ ភាគីពាក់ព័ន្ធ | - | ១ | - | - | - |
| | ចំនួនច្បាប់ចម្លងគោលការណ៍ណែនាំ ត្រូវបានបោះពុម្ព | ចំនួនច្បាប់ចម្លងគោលការណ៍ណែនាំ | អាជ្ញាធរមីន | - | ១៥០ | ១៥០ | - | - |
| ***លទ្ធផលរំពឹងទុក ១.២៖*** *យន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃនៃការអនុវត្ត GMAP ត្រូវបានពង្រឹង* | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **សកម្មភាពទី១៖** តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីនរបស់ម៉ាពូ ក្រុមត្រួតពិនិត្យ និងប្រតិបត្តិករ | ចំនួននៃការចុះត្រួតពិនិត្យ | របាយការណ៍ចុះត្រួតពិនិត្យ | អាជ្ញាធរមីន | ២ | ៤ | ៤ | ៤ | ៤ |
| **សកម្មភាពទី២៖** កសាងផែនការសកម្មភាពប្រចាំឆ្នាំ និងទម្រង់របាយការណ៍វឌ្ឍនភាពសកម្មភាពការងារយេនឌ័រប្រចាំត្រីមាសនិងប្រចាំឆ្នាំ របស់ក្រុមការងារយេនឌ័រអាជ្ញាធរមីន | ផែនការសកម្មភាពត្រូវបានកសាង | ផែនការសកម្មភាពប្រចាំឆ្នាំ | CMAA-GT | ១ | ១ | ១ | ១ | ១ |
| | ទម្រង់របាយការណ៍ប្រចាំត្រីមាសនិងប្រចាំឆ្នាំត្រូវបានកសាង | ទម្រង់របាយការណ៍ប្រចាំត្រីមាស | CMAA-GT | ១ | - | - | - | - |
| | | ទម្រង់របាយការណ៍ប្រចាំឆ្នាំ | CMAA-GT | ១ | - | - | - | - |
| **សកម្មភាពទី៣៖** រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមការងារយេនឌ័រអាជ្ញាធរមីន និងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីនយ៉ាងតិចម្តងក្នុងមួយឆ្នាំ | ចំនួនកិច្ចប្រជុំប្រចាំត្រីមាសរបស់ CMAA-GT ត្រូវបានរៀបចំ | របាយការណ៍កិច្ចប្រជុំ | CMAA-GT | ៤ | ៤ | ៤ | ៤ | ៤ |
| | កិច្ចប្រជុំ TRG-Gender ប្រចាំឆ្នាំត្រូវបានរៀបចំ | របាយការណ៍កិច្ចប្រជុំ | អាជ្ញាធរមីន<br>ប្រតិបត្តិករ<br>ភាគីពាក់ព័ន្ធ | ១ | ១ | ១ | ១ | ១ |
| **សកម្មភាពទី៤៖** រៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិ និងពេលបញ្ចប់ការអនុវត្តផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន | ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិត្រូវបានរៀបចំ | របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិ | អាជ្ញាធរមីន<br>ភាគីពាក់ព័ន្ធ | - | - | ១ | - | ១ |
| **យុទ្ធសាស្ត្រទី២៖ ពង្រឹងសមត្ថភាពអាជ្ញាធរមីន ម៉ាពូ ប្រតិបត្តិករ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាន ក្នុងការអនុវត្តគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន** | | | | | | | | |
| ***លទ្ធផលរំពឹងទុក ២.១៖*** *សមត្ថភាពសមាជិកក្រុមការងារយេនឌ័រអាជ្ញាធរមីន ម៉ាពូ ប្រតិបត្តិករ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋានត្រូវបានពង្រឹង* | | | | | | | | |
| **សកម្មភាពទី១៖** បណ្តុះបណ្តាលសមាជិកក្រុមការងារយេនឌ័រអាជ្ញាធរមីន ស្តីពីនីតិវិធីសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន និង GMAP 2021-2025 | ចំនួនវគ្គបណ្តុះបណ្តាលត្រូវបានផ្តល់ | របាយការណ៍វគ្គបណ្តុះបណ្តាល | CMAA-GT | - | ១ | ១ | - | - |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **សកម្មភាពទី២៖** បណ្តុះបណ្តាលមន្ត្រី-បុគ្គលិកអាជ្ញាធរមីន ម៉ាពូ ក្រុមត្រួតពិនិត្យ និងប្រតិបត្តិករក្នុងការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន | ចំនួនវគ្គបណ្តុះបណ្តាលត្រូវបានផ្តល់ | របាយការណ៍វគ្គបណ្តុះបណ្តាល | អាជ្ញាធរមីន ភាគីពាក់ព័ន្ធ | - | ២ | ២ | ១ | - |
| **សកម្មភាពទី៣៖** ប្រមូលទិន្នន័យ និងចងក្រងរបាយការណ៍ប្រចាំឆ្នាំនៃការបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រ ដែលអាជ្ញាធរមីន ម៉ាពូ និងប្រតិបត្តិករទទួលបានពីភាគីពាក់ព័ន្ធ | ចំនួនរបាយការណ៍វគ្គបណ្តុះ-បណ្តាលប្រចាំឆ្នាំត្រូវបានចងក្រង | របាយការណ៍វគ្គបណ្តុះបណ្តាលប្រចាំឆ្នាំ | អាជ្ញាធរមីន ប្រតិបត្តិករ ភាគីពាក់ព័ន្ធ | - | ១ | ១ | ១ | ១ |
| ***លទ្ធផលរំពឹងទុក ២.២៖*** *របាយការណ៍ស្តីពីការកសាងសមត្ថភាពបុគ្គលិកស្ត្រីនៅក្នុងអាជ្ញាធរមីន ម៉ាពូ និងប្រតិបត្តិករ* | | | | | | | | |
| **សកម្មភាពទី១៖** ប្រមូល និងចងក្រងរបាយការណ៍ប្រចាំធមាសនិងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាពបុគ្គលិកស្ត្រីរបស់អាជ្ញាធរមីន | របាយការណ៍ប្រចាំធមាស និងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាពត្រូវបានចងក្រង | របាយការណ៍ប្រចាំធមាស និងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាព | CMAA-GT | - | ២ | ២ | - | - |
| **សកម្មភាពទី២៖** ប្រមូល និងចងក្រងរបាយការណ៍ប្រចាំធមាសនិងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាពបុគ្គលិកស្ត្រីរបស់ម៉ាពូ | របាយការណ៍ប្រចាំធមាស និងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាពត្រូវបានចងក្រង | របាយការណ៍ប្រចាំធមាស និងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាព | អាជ្ញាធរមីន | - | ២ | ២ | - | - |
| **សកម្មភាពទី៣៖** ប្រមូល និងចងក្រងរបាយការណ៍ប្រចាំធមាសនិងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាពបុគ្គលិកស្ត្រីរបស់ប្រតិបត្តិករ | របាយការណ៍ប្រចាំធមាស និងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាពត្រូវបានចងក្រង | របាយការណ៍ប្រចាំធមាស និងប្រចាំឆ្នាំ ស្តីពីការកសាងសមត្ថភាព | អាជ្ញាធរមីន | - | ២ | ២ | - | - |
| **សកម្មភាពទី៤៖** វាយតម្លៃពីតម្រូវការសមត្ថភាពរបស់បុគ្គលិកស្ត្រីនៅក្នុងសកម្មភាពមីន និងស្វែងរកការគាំទ្រមតិលើតម្រូវការសមត្ថភាព ដែលនឹងជួយបុគ្គលិកស្ត្រីឱ្យទទួលបានឱកាសការងារក្រោយឆ្នាំ ២០២៥ | ការសិក្សាវាយតម្លៃតម្រូវការសមត្ថភាពត្រូវបានធ្វើឡើង | របាយការណ៍វាយតម្លៃ | អាជ្ញាធរមីន | - | - | ១ | - | - |
| | ចំនួនកិច្ចប្រជុំ/សិក្ខាសាលាចែករំលែកការរកឃើញ និងអនុសាសន៍ជាមួយភាគីពាក់ព័ន្ធ | របាយការណ៍កិច្ចប្រជុំ/សិក្ខាសាលា | អាជ្ញាធរមីន | - | - | - | ២ | - |
| | ចំនួនកិច្ចប្រជុំតាមដានការអនុវត្តអនុសាសន៍របស់ភាគីពាក់ព័ន្ធត្រូវបានរៀបចំ | របាយការណ៍នៃកិច្ចប្រជុំដាមដាន | អាជ្ញាធរមីន | - | - | - | - | ២ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **យុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការចូលរួមប្រកបដោយស្មើភាពរបស់ស្ត្រី ក្នុងដំណើរការសកម្មភាពមីន ក្នុងសេវាកម្មសម្រាប់អ្នកនៅរស់រានមានជីវិត ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (EORE) និងក្នុងសកម្មភាពស្វែងរកការគាំទ្រមតិ** | | | | | | | | |
| ***លទ្ធផលរំពឹងទុក ៣.១៖*** *ទិន្នន័យដែលមានទិដ្ឋភាពយេនឌ័រ និងទិន្នន័យមានបែងចែកភេទ អាយុ និងពិការភាពដែលអាចយកមកប្រើប្រាស់បាន* | | | | | | | | |
| **សកម្មភាពទី១៖** ពិនិត្យទម្រង់របាយការណ៍ដែលពាក់ព័ន្ធសកម្មភាពមីន ដើម្បីធានាបាននូវបរិយាប័ន្នក្នុងការឆ្លើយតបទៅនឹងយេនឌ័រ និងទិន្នន័យបែងចែកភេទ អាយុ និងពិការភាព | ទម្រង់របាយការណ៍ចំនួន ២៧ ត្រូវបានពិនិត្យ | ទម្រង់របាយការណ៍ដែលបានពិនិត្យ | អាជ្ញាធរមីន UNDP | ២៧ | - | - | - | - |
| **សកម្មភាពទី២៖** រៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធក្នុងវិស័យសកម្មភាពមីន ដើម្បីជូនដំណឹងអំពីបច្ចុប្បន្នភាពនៃទម្រង់របាយការណ៍ | ចំនួនកិច្ចប្រជុំជាមួយអាជ្ញាធរមីន ម៉ាពូ ក្រុមត្រួតពិនិត្យ និងប្រតិបត្តិករត្រូវបានរៀបចំ | របាយការណ៍កិច្ចប្រជុំ | អាជ្ញាធរមីន | - | ២ | - | - | - |
| ***លទ្ធផលរំពឹងទុក ៣.២៖*** *ការចូលរួម និងភាពជាតំណាងស្មើៗគ្នារបស់ស្ត្រី បុរស កុមារី កុមារា និងជនងាយរងគ្រោះត្រូវបានលើកកម្ពស់នៅក្នុងសកម្មភាពមីន តាមរយៈសកម្មភាពស្វែងរកការគាំទ្រមតិជាមួយភាគីពាក់ព័ន្ធ* | | | | | | | | |
| **សកម្មភាពទី១៖** បញ្ចូលការបញ្ជ្រាបយេនឌ័រទៅក្នុងព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹង ដែលរៀបចំឡើងដោយនាយកដ្ឋានទទួលបន្ទុករបស់អាជ្ញាធរមីន | ចំនួនកម្មវិធីលើកកម្ពស់ការយល់ដឹងត្រូវបានចូលរួម | របាយការណ៍សកម្មភាពចូលរួម | អាជ្ញាធរមីន | - | ១ | ១ | ១ | - |
| **សកម្មភាពទី២៖** ប្រមូលទិន្នន័យជនរងគ្រោះដោយសារមីនដែលមានបែងចែកភេទ អាយុ និងពិការភាព ដើម្បីជួយសម្រួលដល់ការទទួលបានសេវាកម្មសមស្របប្រកបដោយសមធម៌ (ការសង្គ្រោះបន្ទាន់ ការថែទាំសុខភាព ការថែទាំរាងកាយ ការថែទាំផ្លូវចិត្ត ការស្តារនីតិសម្បទា ជីវភាពរស់នៅ និងសេវាផ្លូវច្បាប់) | របាយការណ៍បូកសរុបទិន្នន័យ QLS ប្រចាំឆ្នាំត្រូវបានប្រមូល | របាយការណ៍បូកសរុបទិន្នន័យ QLS ប្រចាំឆ្នាំ | CMAA-GT VAD | ១ | ១ | ១ | ១ | ១ |
| | របាយការណ៍បូកសរុបប្រចាំឆ្នាំស្តីពីសេវាកម្មដែលបានផ្តល់ដល់ជនរងគ្រោះត្រូវបានប្រមូល | របាយការណ៍បូកសរុបប្រចាំឆ្នាំស្តីពីសេវាកម្មដែលបានផ្តល់ដល់ជនរងគ្រោះ | CMAA-GT VAD | ១ | ១ | ១ | ១ | ១ |
| | កិច្ចប្រជុំពិនិត្យឡើងវិញលើសម្ភារៈ EORE ត្រូវបានរៀបចំ | របាយការណ៍កិច្ចប្រជុំ | ក្រុមការងារយេនឌ័រ PRD | ១ | ១ | ១ | - | - |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **សកម្មភាពទី៣៖** ពិនិត្យសម្ភារៈ EORE ដើម្បីធានាថា សារអប់រំចំគោលដៅសម្រាប់ស្ត្រី បុរស កុមារី កុមារា និងជនមានពិការភាព ដោយផ្អែកលើការវាយតម្លៃតម្រូវការ | សិក្ខាសាលាដើម្បីធានាឱ្យមាននូវសម្ភារៈ EORE និងសារឱ្យចំគោលដៅត្រូវបានរៀបចំ | របាយការណ៍សិក្ខាសាលា | អាជ្ញាធរមីន ប្រតិបត្តិករ ភាគីពាក់ព័ន្ធ | ១ | ១ | ១ | - | - |
| **សកម្មភាពទី៤៖** បង្កើតស្តង់ដារកម្ពាត់មីនកម្ពុជាស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន | ស្តង់ដារស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីនត្រូវបានកសាង | ស្តង់ដារស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន | អាជ្ញាធរមីន ប្រតិបត្តិករ ភាគីពាក់ព័ន្ធ | - | ១ | - | - | - |
| **សកម្មភាពទី៥៖** ផ្តល់ការគាំទ្រគំនិតផ្តួចផ្តើមរបស់ភាគីពាក់ព័ន្ធ និងចូលរួមព្រឹត្តិការណ៍ក្នុងតំបន់និងសាកល ស្តីពីយេនឌ័រនៅក្នុងសកម្មភាពមីន | ចំនួនសកម្មភាពគាំទ្រដែលផ្តល់ដល់ភាគីពាក់ព័ន្ធ | របាយការណ៍ស្តីពីសកម្មភាព | CMAA-GT | ១ | ១ | ១ | ១ | - |
| | ចំនួនព្រឹត្តិការណ៍ដែលត្រូវបានចូលរួម | របាយការណ៍ចូលរួម | CMAA-GT | ១ | ១ | ១ | - | - |
| **សកម្មភាពទី៦៖** វាយតម្លៃផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើស្ត្រីដែលកំពុងបម្រើការងារក្នុងវិស័យសកម្មភាពមីន | ការវាយតម្លៃផលប៉ះពាល់នៃជំងឺកូវីដ-១៩ ត្រូវបានធ្វើឡើង | របាយការណ៍វាយតម្លៃ | អាជ្ញាធរមីន ប្រតិបត្តិករ ភាគីពាក់ព័ន្ធ | - | ១ | - | - | - |
| ***លទ្ធផលរំពឹងទុក ៣.៣៖*** *ចំនួនស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងចំនួនស្ត្រីបម្រើការងារក្នុង អាជ្ញាធរមីន ម៉ាពូ និងប្រតិបត្តិករ កើនឡើងតាមរយៈការស្វែងរកការគាំទ្រមតិ* | | | | | | | | |
| **សកម្មភាពទី១៖** ស្វែងរកការគាំទ្រមតិដើម្បីបង្កើនចំនួនស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងចំនួនស្ត្រីបម្រើការងារក្នុងអាជ្ញាធរមីន ម៉ាពូ និងប្រតិបត្តិករ | កិច្ចប្រជុំពិភាក្សាដើម្បីស្វែងរកការគាំទ្រមតិត្រូវបានរៀបចំ | របាយការណ៍កិច្ចប្រជុំ | អាជ្ញាធរមីន | - | ១ | ១ | ១ | - |
| **សកម្មភាពទី២៖** សហការជាមួយនាយកដ្ឋានសង្គ្រោះជនពិការដោយសារមីននៃអាជ្ញាធរមីន និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការបង្កើនចំនួនបុគ្គលិកជាស្ត្រីនៅតាមមណ្ឌលស្តារនីតិសម្បទា | កិច្ចប្រជុំពិគ្រោះយោបល់ជាមួយ PWDF/MoSVY ត្រូវបានរៀបចំ | របាយការណ៍កិច្ចប្រជុំ | CMAA-GT<br>VAD | - | ១ | ១ | ១ | - |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **សកម្មភាពទី៣៖** ផលិតករណីសិក្សា និងវីដេអូ ស្តីពីស្ត្រីបម្រើការងារក្នុងវិស័យសកម្មភាពមីន | ករណីសិក្សា និងវីដេអូត្រូវបានផលិត | ករណីសិក្សា និងវីដេអូស្តីពីស្ត្រីបម្រើការងារក្នុងវិស័យសកម្មភាពមីន | អាជ្ញាធរមីន | - | ករណីសិក្សា ១ វីដេអូ ១ | - | - | - |